# *សិលាចារឹកទួលស្រែភូមិ ខេត្តបាត់ដំបង* K.1050

*សិលាចារឹកនះ រកឃើញនៅទួលស្រែភូមិដែលមានទីតាំងស្ថិតនៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ហើយបានយកមករក្សាទុកនៅសារមន្ទីរវត្តពោធិវាល ក្រុងបាត់ដំបង។ ដោយទទួលបានការអនុញ្ញាតពី លោក តុប តានលាន អតីតប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង និងលោក គឹម សោភ័ណ នៅក្នុងឆ្នាំ២០១២ ខ្ញុំបាទ និងសហការី បានចុះផ្តិតនិងសិក្សាសិលាចារឹកនេះ។ តើសិលាចារឹករកឃើញនៅទួលស្រែភូមិ ខេត្តបាត់ដំបង មានអត្ថន័យ និងខ្លឹមសារយ៉ាងណាខ្លះ?*

*សិលាចារឹកនេះ ចារឹកអក្សរទាំងសងខាងនៅលើផ្ទៃបង្គោលថ្មភក់រាងជាស្លឹកសីមា ជាភាសាខ្មែរ និងភាសាសំស្ក្រឹត មានចំនួនសរុប ៣៧ បន្ទាត់ (ជ្រុងទី១ មានចំនួន ២៣ បន្ទាត់ និងជ្រុងទី២ មានចំនួន ១៤ បន្ទាត់)។ ខ្លឹមសារទាំងមូល គឺរៀបរាប់អំពីមន្ត្រីម្នាក់មានគោរម្យងារជា "ម្រតេញ" ដែលមានឈ្មោះថា "ម្រតាញវគ្រ្កសិវទុលោ ដែលជាអធិបតីគ្រប់គ្រងទេវស្ថានកម្រតេងអញបរមេស្វរ។ កម្រតេង អញបរមេស្វរ ជាឈ្មោះទេវស្ថានមួយកន្លែង ដែលអាចជាឈ្មោះដើម ឬទេព នៅក្នុងទេវស្ថានទួលស្រែភូមិនេះតែម្តង ប៉ុន្តែសព្វថ្ងៃអ្នកស្រុកហៅថា «**ទួលស្រែភូមិ**»។ ពាក្យថា «បរមេឝ្វរ» ជាភាសាសំស្ក្រឹត ឬអានជាខ្មែរថា "បរមេសូរ" ជាព្រះនាមរបស់ព្រះសិវ ប៉ុន្តែនៅក្នុងរជ្ជកាលរបស់ព្រះស្រីជយវម៌្មទេវទី២ បន្ទាប់អំពីទ្រង់សោយព្រះវិលាល័យទៅទ្រង់ព្រះនាមថា បរមេស្វរ ដែរ។ បរមេស្វរ គឺជាបដិមាព្រះសិវលិង្គដ៏ពិសិដ្ឋសម្រាប់ព្រហ្មញ្ញសាសនា និងជនជាតិខ្មែរនៅសម័យបុរាណដែរ។*

*ចារឹកនេះ ជាប្រភេទរាជសាសន៍ស្រមតាមការទូលស្នើសុំរាជប្រទានផ្តល់រាជានុគ្រោះ ប៉ុន្តែមិនបានបញ្ជាក់ព្រះនាមព្រះមហាក្សត្រដោយចំពោះនោះទេ។ អ្នកស្នើសុំគឺ ម្រតេញវគ្រ្កសិវទុលោ ក្នុងមហាសករាជឆ្នាំ ៨២៤ ត្រូវនឹងគ.ស.៩០២ ហើយសេចក្តីណែនាំនោះក៏ចេញនៅក្នុងពេលនោះដែរ។ តួអង្គសំខាន់ផ្សេងទៀតនៅក្នុងអត្ថបទសិលាចារឹកនេះគឺ វាបសិវេស្វរ ត្រូវជាបង ឬប្អូនថ្លៃរបស់វាបវគ្រ្កសិវទុលោ ដែលជាអ្នករស់នៅក្នុងទីតាំងនេះ ហើយក៏ទទួលផលមត៌កបន្តត្រកូលរបស់គាត់ផង ដោយវាបវគ្រ្កសិវទុលោ ជាប្រធានអធិកាបតីទេវស្ថាន បានទូលស្នើសុំព្រះមហាក្សត្រឱ្យរាជានុគ្រោះ និងផ្តល់សិទ្ធិពិសេសដល់គាត់ក្នុងការទទួលផល និងគ្រប់គ្រងទេវស្ថាន។ ស្របតាមការទូលស្នើសុំនេះ ព្រះមហាក្សត្របានត្រាស់បង្គាប់ដល់រាជប្រត្យយ (មន្ត្រីជំនិត) ម្នាក់ ដែលមិនបានបញ្ជាក់ឈ្មោះ ដើម្បីឱ្យមកសង់សិលាចារឹក និងបោះបង្គោលព្រំសីមា កម្មសិទ្ធិ របស់ទេវស្ថានមួយមាននាមថា «**ព្រះកម្រតេងអញបរមេស្វរ**» ដោយព្រះរាជប្រសាទ (ចិត្តសទ្ធាថ្វាយ), រាជានុគ្រោះ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

ផ្តល់សិទ្ធិពិសេសដល់ទេវស្ថាននេះ និងមិនស្ថិតនៅក្រោមចំណុះអាជ្ញាធម៌ណាមួយឡើយ រួមបញ្ចូលទាំងភ្នាក់ងារប្រមូលពន្ធស្រូវអង្ករ  ភ្នាក់ងារប្រមូលពន្ធប្រេងជាដើម  ហើយចំណុះឱ្យតែទេវស្ថានព្រះកម្រតេងអញបរមេស្វរតែមួយគត់។ នៅពេលទ្រង់ចេញព្រះរាជសាសន៍(សេចក្តីបង្គាប់) ទ្រង់បានប្រទានតង្វាយបន្ថែម ដូចជា ដីស្រែជនាទ្វ័ន ស្រែចិក្បុកេត ស្រែកម្ពួ ស្រែផ្ទៃស្រុក ស្រែកណ្តាលស្រែពស់ ស្រែប្រោល និងខ្ញុំបម្រើបុរសចំនួន ៥ នាក់ ក្មេងទើបចេះរត់ម្នាក់ នារីចំនួន ៥ នាក់ កូន ៣ នាក់ គោ ៤ ក្បាល ក្របីចំនួន ៤ ក្បាលថែមទៀតផង។

## អត្ថបទពាក្យចារឹក

### ជ្រុងទី១

១.	សិទ្ធិស្វស្តិឱំនមក្ឝិវាយ
២.	៨២៤ឝកកនុម្រតេញ៑វក្រ្តគិវទុលៅ
៣.	នាវ្រះកម្រតេង៑អញ៑បរមេឝ្វរបង្គំ
៤.	ថ្ស្វង៑និវេទនគិស្រុកភូម្យាករនាអ
៥.	ង្វយ៑វាបគិវេឝ្វរតខ្លាយឱយ៑នុវឧបា
៦.	យ៑នុវខ្ទុមនុវទ្រវ្យផោងនុវស្រេត
៧.	គិវាប៑គិវេឝ្វរថ្ងៃនុវស្រេនិម៌្វលនុវស្រេម្វ
៨.	តកធនស្វមបិថ្លេចំនាំតវ្រះកម្រតេង៑
៩.	អញ៑បរមេឝ្វរតតន្ទុលឯកប្រស្លប្រតិទិ
១០.	នមានវ្រះឝាសនធូលីវ្រះបាទធូលីជេង៑
១១.	វ្រះកម្រតេង៑អញ៑ប្រេប្រត្យយមោក៑ស
១២.	ង៑ប្រឝស្តតគិស្រុក៑សង្គោលតគិស្រេឱយ្ត
១៣.	ម្រតេញ៑វក្រ្តគិវទុលៅនាវ្រះកម្រតេ
១៤.	ង៑អញ៑បរមេឝ្វរនុវឧបាយនុវទ្រ
១៥.	វ្យផោងប្រេថ្ងៃចំនាំវ្រះកម្រតេងអញ៑
១៦.	បរមេឝ្វរនុគិស្រេជនាទ្វ័នស្រេចិក្បុ
១៧.	កេតស្រេកទម្វស្រេផ្លៃស្រុកស្រេក
១៨.	ន្តាលស្រេវសស្រេប្រោលិខ្ញុំឃោ៥រត១តៃ៥ក្វន៣
១៩.	ថ្ម៉ុរ៤ក្របី៤ប្រិហិអនុក្តាគម សិទ្ធិ
២០.	បិប្រេតគិកាយ៌្យវ្រះកម្រតេង៑អញ៑ប
២១.	រមេឝ្វរនេះភូម្យាករនេះវ្វំជាបិស្វត

អត្ថបទដោយ៖ កំ វណ្ណារ៉ា

២២.　ន្រ្តតខ្លោញព្រហិរំជាបិស្វតន្រ្តត

២៣.　ខ្លោញកន្ទារប្រលោរំជាបិស្វតន្រ្ត

*ជ្រុងទី២*

១.　តប្រត្យយល្វោហៅរំជាបិស្វតន្រ្ត

២.　តប្រត្យយបយ៉្យងរំជាបិស្វតន្រ្ត

៣.　នាម្វាយទៃតិលេងនាវ្រះកម្រតេង៑

៤.　អញបរមេគ្វរគុស៑រំអាច្តិអាចា

៥.　យ៉្យខ្លោញរំប្រេអ្នកនោះតគិកាយ៉្យ

៦.　តទៃតិថ្នាថ្លេចំនាំនោះហគុស៑អា

៧.　យត្តតកម្រតេញវ្រក្តគិរទុលៅនុ

៨.　វកុលទៃកុលេយជមានឱក្ក

៩.　កល្បនាបរ្យង៑មាស៑១

១០.　ល្វោលិះ៥ប្រតិសំវត្សរ

១១.　៙ស្យាលក្ផិវេគ្វរោយោ

១២.　ម្ទូតស្តទីយំបរិគ្រហម៑តេ

១៣.　បរមេគ្វរបូជាចំ

១៤.　ន្ទ្របាជ្វយាវាបវ្រក្តគិរ

*បំណាកប្រែ*

*ជ្រុងទី១*

(១) *សិទ្ធិ* (*សេចក្តីសម្រេច*) *ស្វស្តិ* (*សួស្តី*) *ឱំ នមគ្ឝិវាយ* (*ឱម សូមក្រាបថ្វាយបង្គំ ចំពោះព្រះសិវៈ*)។

(២-៩) *មហាសករាជឆ្នាំ៨២៤ ម្រតេញវក្រ្តសិវទុលោ នៅនាព្រះកម្រតេងអញបរមេស្វរថ្វាយបង្គំ ស្តីពីមូលនិធិមាន ស្រុកភូម្យាករ* (*ភូមិករ=ពន្ធដីធ្លី*) *អ្នកដែលរស់នៅ វាបសិវេស្វរ ដែលជាញាតិខ្វាយ* (*សាច់ថ្លៃ*) *បានប្រគល់ឱ្យនូវឧបាយ* (*គ្រឿងផ្សេងៗ ឬមធ្យោបាយសម្រាប់ផ្គត់ផ្គង់*) *នូវខ្ញុំបម្រើ និងទ្រព្យសម្បត្តិផង និងដីស្រែដែលវាបសិវេស្វរបានធ្វើ និងស្រែនិម្នូល និងដីស្រែដែលជាម្ទូតកធន* (*មត៌ក*) *សូម ដើម្បីរៀបចំធ្វើជារណ្តាប់តង្វាយបូជាដល់ ព្រះកម្រតេងអញបរមេស្វរ* (*តង្វាយមាន*) *តន្ទុល* (*អង្ករ*) *ចំនួន ១ ប្រស្ថជាប្រចាំថ្ងៃ*។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

(១០-១៦) ព្រះមហាក្សត្រ ទ្រង់មានព្រះសាសន៍ (ព្រះរាជឱង្ការត្រាស់បង្គាប់) ធូលីព្រះបាទធូលីជេងព្រះកម្រតេងអញ ដោយត្រាស់បង្គាប់ប្រើប្រត្យយ (រាជជំនិត) ដើម្បីឱ្យមកសង់ប្រសស្ត (បង្គោលចារឹក) នៅស្រុក បោះបង្គោលដីស្រែ ដើម្បីប្រគល់ទៅឱ្យដល់ម្រតេញវក្រ្តសិវទុលៅសម្រាប់នៅនាព្រះកម្រតេងអញបរមេស្វរ នូវ ឧបាយ និងទ្រព្យសម្បត្តិផង។ ព្រះមហាក្សត្រ ទ្រង់ត្រាស់បង្គាប់ប្រើ ដើម្បីធ្វើតង្វាយដល់ព្រះកម្រតេងអញបរមេស្វរ។

(១៦-១៩) តង្វាយ គឺដីស្រែជនាទ្ទំន ស្រែចិក្យកេត ស្រែក្មុត ស្រែផ្ទៃស្រុក ស្រែកណ្តាល ស្រែពស់ ស្រែប្រោល និងខ្ញុំបម្រើបុរសចំនួន ៥ នាក់ ក្មេងទើបចេះរត់ម្នាក់ នារីចំនួន ៥ នាក់ កូន ៣ នាក់ គោ ៤ ក្បាល ក្របីចំនួន ៤ ក្បាល។

(១៩-១៩) ប្រិតិ អនុក្តាគម សិទ្ធិ សេចក្តីសោមនស្ស អនុក្តាគម (មិនពោលស្តី ឬតុណ្ហីភាព) សេចក្តីសម្រេច ដើម្បីប្រើការសម្រាប់ព្រះកម្រតេងអញបរមេស្វរ នេះភូម្យាករ (ដីឃ្វីបង់អាករ) នេះពុំស្ថិតនៅក្រោមបង្គាប់ចំណុះខ្លោញវ្រីហិ (ប្រធានខាងប្រមូលពន្ធជាស្រូវ) ពុំស្ថិតនៅក្រោមចំណុះខ្លោញ កន្ទារប្រលោ ពុំស្ថិតនៅក្រោមចំណុះ....។

**ជ្រុងទី២**

(១-១០) ដែលជាប្រត្យយ (រាជជំនិត) ល្ងោ ហៅពុំស្ថិតនៅក្រោមចំណុះឱ្យប្រត្យ (ឋានន្តរសារមន្ត្រីត្រួត) ប្រេង ពុំស្ថិតនៅក្រោមចំណុះណាមួយផ្សេង តែស្ថិតនៅក្រោមចំណុះព្រះកម្រតេងអញបរមេស្វរតែមួយគត់។ មិនអាចអាចារ្យ ខ្លោញក្នុំ (ចៅអាវាសទេវស្ថាន) ប្រើអ្នកទាំងអស់នោះដើម្បីធ្វើការផ្សេង (ខុសមុខការ) គឺប្រើសម្រាប់ធ្វើចំណាំសម្រាប់ថ្វាយដល់ទេវស្ថានមួយគត់ ហើយត្រូវស្ថិតនៅក្រោមបង្គាប់កម្រតេញវក្រ្តសិវទុលៅ និងគ្រួសារអ្នកយជមានផង កល្បនា(តង្វាយ) ប្រេងចំណុះ១មាស លួ ចំនួន៥លិះ រៀងរាល់ឆ្នាំ។

(១១-១៤) ស្យាលគ្និវេគ្វ ពោយោ ម្វុតស្តទីយំ បរិគ្រហមិ តេ បរមេគ្វរ បូជា ចំន្ទ្របាផ្សយា វាប វក្រ្តគិវ៙ គ្រឿងតង្វាយនេះ ជាម្វុតកធន (ទ្រព្យមរតក) របស់សិវេស្វរ ជាសាច់ថ្លៃ មត៌កធន (ទ្រព្យមត៌ក) របស់សិវេស្វរនោះបានបូជាដល់ព្រះបរមេស្វរ និងវាបវក្រ្តសិវតាមរាជបញ្ជារបស់ព្រះមហាក្សត្រ។

សរុបជារួមមក សិលាចារឹកទួលស្រែភូមិ ខេត្តបាត់ដំបង គឺជាព័ត៌មានមួយដែលនិយាយពីបញ្ហាសង្គមនៅសម័យអង្គរ និងរៀបរាប់អំពីការធ្វើបុណ្យទាននៅតាមប្រាសាទតាមបែបព្រហ្មញ្ញ

អត្ថបទដោយ៖ កំ វណ្ណាវ៉ា

សាសនា។ ព័ត៌មានជាច្រើននៅក្នុងសិលាចារឹកនេះ នាំឱ្យយើងបានស្គាល់ឈ្មោះមន្ត្រីជាច្រើន ដែលបានបម្រើការនៅសម័យអង្គរ។





រូបលេខ១ និង២៖ ក្រុមការងារចុះផ្តិតសិលាចារឹកនៅសារមន្ទីរវត្តពោធិវាល ក្រុងបាត់ដំបង






រូបលេខ៣ និង៤៖ ទីតាំងរកឃើញសិលាចារឹកទួលស្រែភូមិ ក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង

KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា





*រូបលេខ៥ និង៥ ក្រដាសផ្តិតសិលាចារឹកទួលស្រែភូមិ (ផ្តិតដោយៈ កំ វណ្ណារ៉ា និងសហការី)*

*អត្ថបទដោយៈ កំ វណ្ណារ៉ា*